# ជូនចំពោះក្រុមហ៊ុនទទួលនិងអ្នកហាត់រៀន

ពេលដែលអ្នកហាត់រៀនទៅមន្ទីពេទ្យ សូមយក«សំបុត្រពីការព្យាបាលនៃអ្នកហាត់រៀនAOTS»(នៅខាងក្រោមថែងថា«កាតវេជ្ជសាស្ត្រ») «វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ»និង«សេចក្តីស្នើសុំសម្រាប់ពេលអ្នកហាត់រៀនAOTSទៅមន្ទីពេទ្យ»(ដាក់កាតវេជ្ជសាស្ត្រ)ទៅជាមួយផង ហើយសូមធ្វើតាមការណែនាំដូចខាងក្រោម។ (បើទទួលថ្នាំនៅខាងក្រៅមន្ទីពេទ្យ សូមធ្វើដូចនេះនៅឱសថស្ថាន) ហើយពេលទៅមន្ទីពេទ្យ សូមទៅជាមួយនឹងបុគ្គលិកម្នាក់របស់ក្រុមហ៊ុនទទួលផង។

## នៅកន្លែងទទួលភ្ញៀវនៃមន្ទីពេទ្យ



| AOTS研修生の診療に関する証明書 | 研修生No.999999 |
|---|---|
| 氏　名 XXXXXXXXXXXXXXXX | |
| 受入企業 一般財団法人　海外産業人材育成協会 | |
| XXXX年XX月XX日 － XXXX年XX月XX日 | |
| XXXXXXXXXX | |
| XXXX.XX.XX | XXXX |
| XXXX年XX月XX日 | |

（一財）海外産業人材育成協会
（AOTS）



研修生個人別診療費請求書

សូមបង្ហាញ«សំបុត្រពីការព្យាបាលនៃអ្នកហាត់រៀនAOTS»(កាតវេជ្ជសាស្ត្រ) និង«សេចក្តីស្នើសុំសម្រាប់ពេលអ្នកហាត់រៀនAOTSទៅមន្ទីពេទ្យ»ដល់អ្នកទទួលភ្ញៀវ។

(កំណត់សម្គាល់)កាតនេះអាចប្រើបានសម្រាប់ថ្លៃព្យាបាលពេលមានជម្ងឺឬរបួសគ្រោះថ្នាក់ណាមួយដែលបានកើតឡើងក្នុងរយៈពេលហាត់រៀន។
កាតនេះមានសុពលភាពក្នុងរយៈពេល១៨០ថ្ងៃគិតចាប់ពីថ្ងៃទៅមន្ទីពេទ្យជាលើកទីមួយឬថ្ងៃដែលត្រូវរបួស។

សូមកត់ពត៍មានចាំបាច់ដូចជាឈ្មោះអ្នកហាត់រៀន រោគសញ្ញាឈ្មោះអ្នកទទួលស្គាល់ស្ថានភាពជាដើមលើ«វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ»រួចឲ្យដល់អ្នកទទួលភ្ញៀវ។

← សូមកត់ពត៍មាននៅក្នុង«កាតវេជ្ជសាស្ត្រ»។

← សូមកត់ពត៍មានចាំបាច់ដូចជារោគសញ្ញា ថ្ងៃខែដែលចាប់ផ្តើមឈឺជាដើម។
ជាអ្នកទទួលស្គាល់ស្ថានភាព សូមកត់ឈ្មោះរបស់អ្នកដែលទៅជាមួយគ្នាឬអ្នកទទួលខុសត្រូវខាងការបង្ហាត់ឬអ្នកដឹកនាំខាងជីវភាពជាដើម។

## របៀបបង់ថ្លៃវេជ្ជសាស្ត្រ

១)ករណីអ្នកហាត់រៀនមិនបង់ថ្លៃវេជ្ជសាស្ត្រដល់មន្ទីពេទ្យ

ដោយសារសេចក្តីសប្បុរសរបស់មន្ទីពេទ្យ មន្ទីពេទ្យមិនតម្រូវឲ្យអ្នកជម្ងឺបង់ថ្លៃវេជ្ជសាស្ត្រនៅឯកន្លែងទទួលភ្ញៀវទេ តែមន្ទីពេទ្យនឹងផ្ញើ«វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ»ដល់AOTSដើម្បីស្នើសុំបង់ថ្លៃវេជ្ជសាស្ត្រ នោះក្រុមហ៊ុនធានារ៉ាប់រងនឹងបង់ថ្លៃចំណាយនោះដល់មន្ទីពេទ្យនៅថ្ងៃក្រោយ។ ដូច្នេះ ជាទូទៅមិនមានការបង់ថ្លៃនៅឯកន្លែងទទួលភ្ញៀវឡើយ។

២)ករណីអ្នកហាត់រៀនឬក្រុមហ៊ុនទទួលនឹងបង់ថ្លៃវេជ្ជសាស្ត្រដល់មន្ទីពេទ្យ

មានករណីខ្លះដែលមន្ទីពេទ្យតម្រូវឲ្យបង់ថ្លៃនៅឯកន្លែងទទួលភ្ញៀវដែរ។ ពេលនោះ សូមបង់ថ្លៃផង។
ក្នុងករណីនោះ បើក្រុមហ៊ុនទទួលនឹងផ្ញើ «វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ» ដល់AOTS នោះក្រុមហ៊ុនធានារ៉ាប់រងនឹងបង់ថ្លៃវេជ្ជសាស្ត្រដល់ក្រុមហ៊ុនទទួល។

＜របៀបស្នើសុំថ្លៃវេជ្ជសាស្ត្រ＞

①កត់ថ្ងៃខែដែលទៅមន្ទីពេទ្យដំបូងនិងឈ្មោះជម្ងឺឬរបួសនៅក្បែរជួរអ្នកទទួលស្គាល់ស្ថានភាពក្នុងវិក័យប័ត្រនោះ(ករណីរបួស កត់ពីថ្ងៃខែដែលត្រូវរបួស)

②កត់ឈ្មោះក្រុមហ៊ុនទទួលនៅជួរអ្នកស្នើសុំថ្លៃវេជ្ជសាស្ត្រក្នុងវិក័យប័ត្រនោះ ហើយកត់លេខគណនីធនាគាររបស់ក្រុមហ៊ុនទទួលជាអ្នកទទួលលុយ។

③ផ្ញើវិក័យប័ត្រនោះនិងបង្កាន់ដៃបង់ប្រាក់(ដើម)ដល់AOTS។

④នៅចុងខែបន្ទាប់ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្ញើលុយចូលក្នុងគណនីធនាគារជាកំណត់។

## ករណីបង់ថ្លៃនៅឱសថស្ថាន

ពេលត្រូវបង់ថ្លៃថ្នាំនៅឱសថស្ថាន សូមបង្ហាញ«វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ» «កាតវេជ្ជសាស្ត្រ» និង«សំបុត្រពីការព្យាបាលនៃអ្នកហាត់រៀនAOTS» ដូចករណីដែលបានថែងនៅខាងលើ។ របៀបបង់ថ្លៃក៍ដូចគ្នាដែរ។ ប៉ុន្តែពេលដែលក្រុមហ៊ុនទទួលត្រូវបង់ថ្លៃថ្នាំដល់ឱសថស្ថាន សូមសរសេរពីថ្ងៃខែដែលទៅមន្ទីពេទ្យជាលើកដំបូង ឈ្មោះជម្ងឺ និងឈ្មោះមន្ទីពេទ្យនៅក្បែរជួរអ្នកទទួលស្គាល់ស្ថានភាពក្នុង «វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់ រៀនម្នាក់ៗ»។

## ទំនាក់ទំនង

The Association for Overseas Technical Cooperation and Sustainable Partnerships (AOTS）
Corporate Liaison Group Ⅰ, Corporate Liaison Department
30-1, Senju-Azuma 1-chome, Adachi-ku, Tokyo 120-8534, Japan　TEL: +81-3-3888-8220　FAX: +81-3-3888-8428
URL：www.aots.jp